សុន្ទរកថា
សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង ជាប្រធាន គ.ជ.អ.ប
ក្នុងពិធីផ្សព្វផ្សាយស្តីពីការដាក់ឱ្យអនុវត្តអនុក្រឹត្យ ស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងអនុក្រឹត្យស្តីពីការប្រគល់មុខងារគ្រប់គ្រង និងផ្តល់សេវាសុខាភិបាលទៅឱ្យរដ្ឋបាលរាជធានីខេត្ត

សាលប្រជុំក្រសួងមហាផ្ទៃ, ថ្ងៃអង្គារ ៦ រោច ខែមិគសិរ ឆ្នាំកុរ ឯកស័ក ពុទ្ធសករាជ ២៥៦៣
ត្រូវនឹងថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៩

- **ឯកឧត្តម លោកជំទាវសមាជិក សមាជិកាព្រឹទ្ធសភា និងរដ្ឋសភា**
- **ឯកឧត្តម លោកជំទាវទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ**
- **ឯកឧត្តម លោកជំទាវតំណាងឧត្តមក្រុមប្រឹក្សាពិគ្រោះ និងផ្តល់យោបល់**
- **ឯកឧត្តមលោកជំទាវប្រធានក្រុមប្រឹក្សា និងអភិបាលរាជធានី ខេត្ត**
- **លោក លោកស្រីប្រធានមន្ទីរ ប្រធានក្រុមប្រឹក្សា អភិបាលក្រុង ស្រុក ខណ្ឌ**
- **លោក លោកស្រីតំណាងដៃគូអភិវឌ្ឍន៍ សង្គមស៊ីវិល និងវិស័យឯកជន**
- **អស់លោក លោកស្រីជាសមាជិក សមាជិកានៃអង្គពិធីជាទីមេត្រី !**

ជាបឋម ក្នុងនាមរាជរដ្ឋាភិបាល ក្នុងនាម គ.ជ.អ.ប និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះឯកឧត្តម លោកជំទាវ អស់លោក លោកស្រី និងភ្ញៀវកិត្តិយសទាំងអស់ដែលបានអញ្ជើញចូលរួមក្នុង "**ពិធីផ្សព្វផ្សាយស្តីពីការដាក់ឱ្យអនុវត្តអនុក្រឹត្យស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងអនុក្រឹត្យស្តីពីការប្រគល់មុខងារគ្រប់គ្រង និងផ្តល់សេវាសុខាភិបាលទៅឱ្យរដ្ឋបាលរាជធានី ខេត្ត**" ដ៏មានសារៈសំខាន់នាថ្ងៃនេះ។ ខ្ញុំយល់ថា នេះជាព្រឹត្តិការណ៍ជាប្រវត្តិសាស្ត្រនៃការកែទម្រង់ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលសាធារណៈនៅថ្នាក់ក្រោមជាតិ តាមគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ សំដៅធានាដល់ការផ្ទេរសិទ្ធិ ផ្ទេរអំណាច ផ្ទេរមុខងារ និងធនធានឱ្យទៅរដ្ឋបាលថ្នាក់ក្រោមជាតិដែលនៅកៀកជិតប្រជាពលរដ្ឋក្នុងការទទួលខុសត្រូវលើការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់សិទ្ធិ អំណាច និង

ធនធានទាំងនោះសម្រាប់ការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋាន ឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋប្រកបដោយប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព បរិយាប័ន្ន និងសមធម៌សង្គម។

ការរៀបចំ និងដាក់ឱ្យអនុវត្តនូវអនុក្រឹត្យស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងអនុក្រឹត្យស្តីពីការប្រគល់មុខងារគ្រប់គ្រង និងផ្តល់សេវាសុខាភិបាលទៅឱ្យរដ្ឋបាលរាជធានី ខេត្តទាំងនេះ គឺជាសមិទ្ធផលជាប្រវត្តិសាស្ត្រថ្មីមួយរបស់រាជរដ្ឋាភិបាលដែលកើតចេញពីកិច្ចសហការរវាងកម្មវិធីកំណែទម្រង់ស្នូលទាំង៣រួមមាន កំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ កំណែទម្រង់ការរដ្ឋបាលសាធារណៈ និងកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ព្រមទាំងការគាំទ្រ និងការចូលរួមយ៉ាងសកម្មរបស់ឯកឧត្តម លោកជំទាវ អស់លោក លោកស្រីដែលជាថ្នាក់ដឹកនាំ និងជាមន្ត្រីជំនាញនៃក្រសួង ស្ថាប័នតាមវិស័យនានាទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល និងផ្នែកឯកជន។ ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមវាយតម្លៃខ្ពស់ និងសូមសម្តែងនូវការកោតសរសើរដោយស្មោះចំពោះឯកឧត្តម លោកជំទាវ អស់លោក លោកស្រីទាំងអស់ដែលបានផ្តល់កិច្ចសហការ ការគាំទ្រ និងការចូលរួមប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ក្នុងការជំរុញការអនុវត្តកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការឱ្យមានការវិវឌ្ឍទៅមុខ ស្របតាមគោលនយោបាយ និងរបៀបវារៈនៃការអភិវឌ្ឍជាតិ។ **ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី**!

ឆ្លៀតក្នុងឱកាសនៃការជួបជុំគ្នានាថ្ងៃនេះ ខ្ញុំសូមគូសបញ្ជាក់ជាថ្មីថា **រាជរដ្ឋាភិបាលកម្ពុជាបានតម្កល់នូវឆន្ទៈនយោបាយដ៏មោះមុតលើការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ** ឬហៅថា **កំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ** សម្រាប់រយៈពេលវែង។ ក្នុងក្របខ័ណ្ឌនៃការលើកកម្ពស់អភិបាលកិច្ច រាជរដ្ឋាភិបាលបានចាត់ទុកកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ គឺជាកំណែទម្រង់ស្នូលមួយក្នុងចំណោមកំណែទម្រង់ស្នូល៣ផ្សេងទៀត រួមមាន កំណែទម្រង់រដ្ឋបាលសាធារណៈ កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដែលជាកំណែទម្រង់ស្នូលនៃយុទ្ធសាស្ត្រចតុកោណតាមដំណាក់កាលនីមួយៗរបស់រាជរដ្ឋាភិបាល។

ផ្អែកតាមបទពិសោធន៍ក្នុងបណ្តាប្រទេសជាច្រើនទាំងនៅក្នុងតំបន់ និងលើពិភពលោក កំណែទម្រង់វិមជ្ឈការត្រូវបានឱ្យតម្លៃថា ជាមធ្យោបាយដ៏មានប្រសិទ្ធភាពសម្រាប់ការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់ធនធានសាធារណៈក្នុងការអភិវឌ្ឍមូលដ្ឋាន និងផ្តល់សេវាជូនប្រជាពលរដ្ឋប្រកបដោយការឆ្លើយតប តម្លាភាព គណនេយ្យភាព បរិយាប័ន្ន និងសមធម៌សង្គម។ ទោះយ៉ាងនេះក្តី ការរៀបចំ និងការអនុវត្តកំណែទម្រង់វិមជ្ឈការនៅតាមប្រទេសនីមួយៗមានលក្ខណៈផ្សេងៗគ្នា គឺអាស្រ័យទៅតាមស្ថានភាពភូមិសាស្ត្រ ប្រជាសាស្ត្រ នយោបាយ សេដ្ឋកិច្ច

សង្គមកិច្ច វប្បធម៌ និងប្រពៃណីនៃប្រទេសនីមួយៗ។

ក្នុងបរិបទប្រទេសកម្ពុជា ការរៀបចំ និងការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ គឺដើម្បីធានាដល់ការសម្រេចបាននូវគោលបំណងសំខាន់ៗចំនួន៣ រួមមាន៖

ទីមួយ៖ ដើម្បីពង្រឹង និងពង្រីកលទ្ធិប្រជាធិបតេយ្យ សេរី ពហុបក្ស ស្របតាមស្មារតីនៃរដ្ឋធម្មនុញ្ញរបស់ព្រះរាជាណាចក្រកម្ពុជា។ ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់សម្រាប់អាណត្តិទី១ឆ្នាំ២០០២ ការបោះឆ្នោតបង្កើតក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌសម្រាប់អាណត្តិទី១ឆ្នាំ២០០៩ និងសម្រាប់អាណត្តិជាបន្តបន្ទាប់រហូតមកដល់ពេលនេះ គឺជាការពង្រឹង និងពង្រីកនូវភាពជាតំណាងសាធារណៈ និងការចូលរួមរបស់ប្រជាពលរដ្ឋតាមបែបប្រជាធិបតេយ្យ ដែលប្រការនេះបានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការថែរក្សាសន្តិភាព ស្ថេរ ភាពនយោបាយ ដើម្បីផ្តល់នូវកាលានុវត្តភាពសម្រាប់ការរួមគ្នាកសាងប្រទេសជាតិ ផ្អែកលើបរិបទ និងស្ថានភាពជាក់ស្តែងរបស់កម្ពុជា។ ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ គឺជាតួអង្គដ៏សំខាន់ក្នុងការដឹកនាំ គ្រប់គ្រងរដ្ឋបាលមូលដ្ឋានតាមគោលការណ៍អភិបាលកិច្ចតាមបែបប្រជាធិប តេយ្យ ដែលធានាដល់ការពង្រឹងនូវសិទ្ធិអំណាចរបស់សហគមន៍ និងការចូលរួមរបស់ប្រជាពល រដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួននៅតាមមូលដ្ឋាននីមួយៗ។

ទីពីរ៖ ដើម្បីលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន។ ការធ្វើវិមជ្ឈការ គឺដើម្បីផ្ទេរសិទ្ធិអំណាច មុខងារ និងធនធានទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិទទួលខុសត្រូវលើការគ្រប់គ្រង ការចាត់ចែងសម្រាប់ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន។ ប្រការនេះបានធ្វើឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិដែលនៅកៀកជិតប្រជាពលរដ្ឋមានលទ្ធភាព មានភាពម្ចាស់ការ និងការទទួលខុសត្រូវច្បាស់លាស់ក្នុងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានដើម្បីឆ្លើយតបទៅនឹងតម្រូវការ និងដោះស្រាយនូវបញ្ហាប្រឈមជាក់ស្តែងនានារបស់ប្រជាពលរដ្ឋនៅតាមមូលដ្ឋាននីមួយៗ ឱ្យបានទាន់ពេលវេលាប្រកបដោយប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព បរិយាប័ន្ន និងសមធម៌សង្គម។

ទីបី៖ ដើម្បីបង្កើនធនធាន និងការចូលរួមរបស់សហគមន៍ និងប្រជាពលរដ្ឋសម្រាប់ការអភិវឌ្ឍមូលដ្ឋាន។ ការធ្វើវិមជ្ឈការតាមបែបប្រជាធិបតេយ្យនឹងជំរុញឱ្យមានការប្រាស្រ័យទាក់ទងកាន់តែមានភាពរស់រវើករវាងរដ្ឋបាលមូលដ្ឋានជាមួយសហគមន៍ និងប្រជាពលរដ្ឋតាមមូលដ្ឋាននីមួយៗ។ ប្រការនេះ បង្កលក្ខណៈងាយស្រួលដល់សហគមន៍ និងប្រជាពលរដ្ឋចូលរួមក្នុងកិច្ចដំណើរការធ្វើសេចក្តីសម្រេចរបស់រដ្ឋបាលមូលដ្ឋាន ក៏ដូចជាបង្កលទ្ធភាពឱ្យរដ្ឋបាលមូលដ្ឋានក្នុងការបង្កើននូវប្រភពធនធានតាមមូលដ្ឋាន ការប្រមូលផ្តុំនូវគំនិតផ្តួចផ្តើមដ៏សម្បូរណ៍បែបនៅតាមមូលដ្ឋាន ការកៀរគរការចូលរួមរបស់ប្រជាពលរដ្ឋនៅតាមសហគមន៍ ជាមតិយោបល់ និង

ការផ្តល់ធនធាននានាសម្រាប់ការអភិវឌ្ឍនៅតាមមូលដ្ឋាននីមួយៗ។

ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី!

ជាការពិតណាស់ កម្ពុជាបានអនុវត្តប្រព័ន្ធគ្រប់គ្រងរដ្ឋបាលសាធារណៈតាមបែប**មជ្ឈការ** ជាយូរឆ្នាំមកហើយ អាស្រ័យហេតុនេះ ការធ្វើកំណែទម្រង់វិមជ្ឈការស្របពេលជាមួយគ្នាទាំងវិមជ្ឈការផ្នែកនយោបាយផង វិមជ្ឈការផ្នែករដ្ឋបាលផង និងវិមជ្ឈការហិរញ្ញវត្ថុផង គឺពិតជាមានភាពសាំញ៉ាំ ស្មុគស្មាញ និងរសើបបំផុត។ នាពេលកន្លងមក ទោះបីមានការដាក់ចេញនូវក្របខ័ណ្ឌយុទ្ធសាស្ត្រវិមជ្ឈការ និងវិសហមជ្ឈការ និងច្បាប់រៀបចំអង្គការដើម្បីផ្តល់នូវយុទ្ធសាស្ត្រ និងគោលការណ៍ជាគន្លឹះនានាក៏ដោយ ក៏រាជរដ្ឋាភិបាលចាំបាច់ត្រូវរៀបចំ និងដាក់ឱ្យអនុវត្តនូវ "**កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ**" រយៈពេល១០ឆ្នាំ (២០១០-២០២០)ដើម្បីផ្តល់ផែនទីបង្ហាញផ្លូវសម្រាប់ការអនុវត្តច្បាប់រៀបចំអង្គការជាជំហានៗ សំដៅធានាដល់ការឯកភាពស្រុះស្រួលគ្នា និងមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ ព្រមទាំងដើម្បីលើកកម្ពស់ការទទួលខុសត្រូវ និងភាពម្ចាស់ការរបស់រាជរដ្ឋាភិបាល។ កម្មវិធីជាតិរយៈពេល១០ឆ្នាំបានផ្តោតទៅលើសមាសធាតុសំខាន់ៗចំនួន៥ ជាអាទិ៍ **១**).ការរៀបចំស្ថាប័នរដ្ឋបាលថ្នាក់ក្រោមជាតិ **២**). ការរៀបចំប្រព័ន្ធគ្រប់គ្រង និងអភិវឌ្ឍធនធានមនុស្សសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ **៣**). ការផ្ទេរមុខងារ និងធនធានទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ **៤**). ការធ្វើវិមជ្ឈការហិរញ្ញវត្ថុ និង**៥**). ការរៀបចំស្ថាប័នគាំទ្រកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។

គិតរហូតមកដល់ពេលនេះ យើងបានរួមសហការគ្នារៀបចំ និងអនុវត្តកម្មវិធីជាតិនេះអស់រយៈពេល**០៩ឆ្នាំ**ហើយ។ កាលពីសប្តាហ៍មុន គ.ជ.អ.ប. ក៏បានរៀបចំសិក្ខាសាលាថ្នាក់ជាតិមួយដើម្បីរៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ២០២០របស់ គ.ជ.អ.ប. ដែលជាផែនការសកម្មភាពប្រចាំឆ្នាំ**ចុងក្រោយ**នៃការអនុវត្តកម្មវិធីជាតិរយៈពេល១០ឆ្នាំ។ ជាទូទៅ ការអនុវត្តកម្មវិធីជាតិអស់រយៈពេល០៩ឆ្នាំកន្លងមកនេះ ទោះបីជាមានភាពយឺតយ៉ាវខ្លះៗ ក៏យើងបានខិតខំសហការគ្នា សម្របសម្រួល និងពុះពារគ្រប់ឧបសគ្គក្នុងការអនុវត្ត និងជំរុញឱ្យកិច្ចដំណើរការកំណែទម្រង់ដ៏សាំញ៉ាំនេះ ឱ្យមានការវិវត្តទៅមុខស្របតាមបរិបទជាក់ស្តែងនៃស្ថានភាពនយោបាយ សេដ្ឋកិច្ច និងសង្គមកិច្ចរបស់យើង ព្រមទាំងសម្រេចបានសមិទ្ធផលធំៗគួរឱ្យកត់សម្គាល់ រួមមានជាអាទិ៍៖

ទី១.ពាក់ព័ន្ធនឹងការរៀបចំស្ថាប័នរដ្ឋបាលថ្នាក់ក្រោមជាតិ

រចនាសម្ព័ន្ធគ្រប់គ្រងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិទូទាំងប្រទេសត្រូវបានកែសម្រួល និងដាក់ឱ្យដំណើរការដោយរលូន ស្របតាមគោលការណ៍អភិបាលកិច្ចតាមបែបប្រជាធិបតេយ្យ។ នីតិវិធីអនុវត្តការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលធានាដល់ការលើកកម្ពស់ការចូលរួម

របស់ប្រជាពលរដ្ឋត្រូវបានបង្កើត និងដាក់ឱ្យអនុវត្ត ជាអាទិ៍ នីតិវិធីរៀបចំកិច្ចប្រជុំ និងវេទិកាពិគ្រោះយោបល់សាធារណៈរបស់ក្រុមប្រឹក្សា នីតិវិធីធ្វើសេចក្តីសម្រេចចិត្តរបស់ក្រុមប្រឹក្សា និងនីតិវិធីគ្រប់គ្រងកិច្ចការរដ្ឋបាល។ល។ ប្រព័ន្ធគ្រប់គ្រងនានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិក៏ត្រូវបានដាក់ឱ្យអនុវត្ត និងកែលម្អជាបណ្តើរៗផងដែរ ដែលក្នុងនោះរួមមាន ប្រព័ន្ធកសាងផែនការ ប្រព័ន្ធផ្នែរមូលនិធិនិងគ្រប់គ្រងហិរញ្ញវត្ថុ ប្រព័ន្ធគ្រប់គ្រងនិងអភិវឌ្ឍធនធានមនុស្ស ប្រព័ន្ធទំនាក់ទំនងអន្តរដ្ឋបាល ប្រព័ន្ធត្រួតពិនិត្យនីត្យានុកូលភាព ប្រព័ន្ធគាំទ្របច្ចេកទេស និងប្រព័ន្ធសម្រុះសម្រួលវិវាទនៅមូលដ្ឋានជាដើម។ គោលការណ៍សម្រាប់ការលើកកម្ពស់សមភាពយេនឌ័រ បរិយាប័ន្ន សមធម៌សង្គម និងយុទ្ធសាស្ត្របង្កើនចំនួនស្ត្រីក្នុងមុខតំណែងគ្រប់គ្រងក៏បានបញ្ជ្រាបទៅក្នុងប្រព័ន្ធគ្រប់គ្រងនានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ផែនការយុទ្ធសាស្ត្រស្តីពីការងារគណនេយ្យភាពសង្គម ក៏បានអនុវត្តក្នុងភាពជាដៃគូយ៉ាងជិតស្និទ្ធជាមួយអង្គការសង្គមស៊ីវិលដើម្បីផ្តល់នូវព័ត៌មានសំខាន់ៗពាក់ព័ន្ធនឹងការប្រើប្រាស់ថវិកាឃុំ សង្កាត់ និងអង្គភាពជំនាញនានានៅតាមមូលដ្ឋាន ព្រមទាំងដើម្បីបង្កលក្ខណៈងាយស្រួលជូនប្រជាពលរដ្ឋក្នុងការចូលរួមតាមដាន ត្រួតពិនិត្យ និងផ្តល់យោបល់កែលម្អលើការអនុវត្តការងាររបស់ក្រុមប្រឹក្សាឃុំ សង្កាត់ និងការផ្តល់សេវារបស់អង្គភាពផ្តល់សេវាកម្មនៅមូលដ្ឋានមួយចំនួនដូចជាសាលាបឋមសិក្សា និងមណ្ឌលសុខភាពផងដែរ។

ក្រៅពីនេះ សមិទ្ធផលដ៏សំខាន់ និងមានលក្ខណៈជាប្រវត្តិសាស្ត្រពាក់ព័ន្ធនឹងការរៀបចំស្ថាប័នរដ្ឋបាលថ្នាក់ក្រោមជាតិ គឺការកែសម្រួលរចនាសម្ព័ន្ធរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ តាមរយៈការដាក់ចេញនូវអនុក្រឹត្យចំនួន៣ ដែលយើងកំពុងផ្សព្វផ្សាយ និងដាក់ឱ្យអនុវត្តនាពេលនេះ។ ទោះបីរចនាសម្ព័ន្ធរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវបានរៀបចំឡើងវិញនាឆ្នាំ ២០១០ម្តងរួចហើយក៏ដោយ ក៏ផ្អែកតាមការវិវឌ្ឍផ្នែកនយោបាយ និងការរីកចម្រើនយ៉ាងឆាប់រហ័សផ្នែកសេដ្ឋកិច្ច និងសង្គមកិច្ច នគរូបនីយកម្ម និងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ជាពិសេសការកើនឡើងយ៉ាងគំហុកនូវតម្រូវការសេវាសង្គម និងសេវាទីប្រជុំជនបានទាមទារឱ្យយើងត្រូវធ្វើការពិនិត្យ និងកែសម្រួលឡើងវិញនូវរចនាសម្ព័ន្ធ និងប្រព័ន្ធផ្តល់សេវារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេសនៅថ្នាក់ក្រុង ស្រុក ខណ្ឌ ដែលជាថ្នាក់រដ្ឋបាលមួយមានវិសាលភាពភូមិសាស្ត្រ និងប្រជាសាស្ត្រសមល្មមក្នុងការបំពេញតួនាទីផ្តល់សេវាជាមូលដ្ឋានមួយចំនួនដោយផ្ទាល់ជូនប្រជាពលរដ្ឋ។ កិច្ចការនេះយើងបានរួមគ្នារៀបចំជាបណ្តើរៗតាំងពីឆ្នាំ២០១៦មក តាមរយៈការរួមគ្នាសិក្សាស្រាវជ្រាវលើក្របខ័ណ្ឌគតិយុត្ត និងស្ថានភាពនៃការអនុវត្តជាក់ស្តែង ព្រមទាំងមេរៀន និងបទពិសោធន៍ក្នុងបណ្តាប្រទេសនានា ទាំងក្នុងតំបន់ និងពិភពលោក។ ជាការពិតណាស់ យើងបានចំណាយពេលវេលាជាច្រើនក្នុងការសហការគ្នាពិនិត្យ ពិភាក្សា ពិគ្រោះ

យោបល់ច្រើនលើកច្រើនសារ ទាំងក្នុងកម្រិតមន្ត្រីបច្ចេកទេស និងថ្នាក់ដឹកនាំក្រសួង ស្ថាប័ន និងអ្នកពាក់ព័ន្ធនានាក្នុងកិច្ចដំណើរការនៃការរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលក្រុង ស្រុក ខណ្ឌទាំងនេះ។ អាស្រ័យហេតុនេះ យើងចាំបាច់ត្រូវបន្តសហការគ្នាអនុវត្តឱ្យបានជោគជ័យតាមស្មារតីនៃអនុក្រឹត្យទាំងនេះ។ តំណាងលេខាធិការដ្ឋាន គ.ជ.អ.ប. នឹងធ្វើបទបង្ហាញជូនអង្គពិធីអំពីខ្លឹមសារលម្អិតនៃអនុក្រឹត្យទាំងនេះ និងកិច្ចការជាអាទិភាពនានាដែលត្រូវរៀបចំ និងអនុវត្តដើម្បីធានាឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌអាចចាប់ផ្តើមដំណើរការតាមរចនាសម្ព័ន្ធថ្មីនេះចាប់ពីដើមឆ្នាំ២០២០នេះតទៅ។

ទី២.ពាក់ព័ន្ធនឹងការគ្រប់គ្រង និងអភិវឌ្ឍធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

លិខិតបទដ្ឋានគតិយុត្តសំខាន់ៗពាក់ព័ន្ធនឹងការរៀបចំបង្កើតប្រព័ន្ធគ្រប់គ្រងបុគ្គលិក និងអភិវឌ្ឍធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត រួមមាន៖ អនុក្រឹត្យធ្វើប្រតិភូកម្មអំណាចទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការគ្រប់គ្រងបុគ្គលិកបម្រើការងារនៅរដ្ឋបាលថ្នាក់ក្រោមជាតិ គោលនយោបាយស្តីពីការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ព្រះរាជក្រឹត្យស្តីពីលក្ខន្តិក:ដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ និងសេចក្តីណែនាំស្តីពីគោលការណ៍ និងនីតិវិធីនៃការគ្រប់គ្រងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ។

នាដើមឆ្នាំ២០១៩នេះ បុគ្គលិកក្របខ័ណ្ឌក្រសួងមហាផ្ទៃចំនួនប្រមាណ**៦.២០០នាក់**ដែលបម្រើការងារនៅរដ្ឋបាលថ្នាក់ក្រោមជាតិ និងបុគ្គលិកក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាដែលបម្រើការងារនៅតាមមណ្ឌលកុមារកំព្រារាជធានី ខេត្ត ក៏ត្រូវបានផ្ទេរទៅស្ថិតក្រោមការគ្រប់គ្រងដោយផ្ទាល់របស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗរួចហើយ។ លើសពីនេះ តាមរយៈអនុក្រឹត្យទាំង៤ដែលប្រកាសផ្សព្វផ្សាយ និងដាក់ឱ្យអនុវត្តនាថ្ងៃនេះ ក៏តម្រូវឱ្យមានការផ្ទេរនូវបុគ្គលិកពីក្រសួង ស្ថាប័ននានាចំនួន**រាប់សិបពាន់នាក់**ឱ្យទៅស្ថិតក្រោមការគ្រប់គ្រងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនាដើមឆ្នាំ២០២០នេះផងដែរ។

ក្រៅពីនេះ ការអភិវឌ្ឍសមត្ថភាពដល់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិអំពីក្របខ័ណ្ឌច្បាប់ និងក្របខ័ណ្ឌអនុវត្តតាមប្រព័ន្ធ និងនីតិវិធីអនុវត្តការងារថ្មីក៏ត្រូវបានផ្តល់ជាប្រចាំ តាមរយៈវគ្គបណ្តុះបណ្តាលខ្លីៗ សិក្ខាសាលា និងការហ្វឹកហាត់ការងារជាក់ស្តែងផងដែរ។ ទន្ទឹមគ្នានេះ សាលាជាតិរដ្ឋបាលមូលដ្ឋានដែលជាយន្តការអចិន្ត្រៃយ៍សម្រាប់ការផ្តល់សេវាអភិវឌ្ឍសមត្ថភាពបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិក៏ត្រូវបានបង្កើត និងដំណើរការជាបណ្តើរៗផងដែរ។

ទី៣.ពាក់ព័ន្ធនឹងការផ្ទេរមុខងារទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ

លិខិតបទដ្ឋានគតិយុត្តសំខាន់ៗពាក់ព័ន្ធនឹងកិច្ចដំណើរការផ្ទេរមុខងារ ត្រូវបានរៀបចំ

និងដាក់ឱ្យអនុវត្ត រួមមានជាអាទិ៍ អនុក្រឹត្យស្តីពីកិច្ចដំណើរការទូទៅនៃការផ្ទេរមុខងារ និងធនធានទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ សេចក្តីណែនាំបច្ចេកទេសស្តីពីការរៀបចំបញ្ជីវិភាគមុខងារ និងសេចក្តីណែនាំស្តីពីការពិនិត្យមើលមុខងារឡើងវិញ ដើម្បីកំណត់មុខងារសមស្រប និងធនធានជាក់លាក់ដែលត្រូវផ្ទេរទៅឱ្យរដ្ឋថ្នាក់ក្រោមជាតិជាដើម។ ទោះបីជាកិច្ចដំណើរការផ្ទេរមុខងារទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិមានភាពយឺតយ៉ាវជាងការរំពឹងទុក ក៏ក្នុងរយៈពេលកន្លងមកមានមុខងារក្នុងវិស័យជាអាទិភាពមួយចំនួន រួមមាន បរិស្ថាន និងធនធានធម្មជាតិ សង្គមកិច្ច អភិវឌ្ឍន៍ជនបទ និងមុខងារផ្តល់សេវារដ្ឋបាលប្រមាណជាង២០០ប្រភេទ ក៏ត្រូវបានផ្ទេរជាបណ្តើរៗ ទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ទាំងក្នុងបែបផែននៃការប្រគល់ និងការធ្វើប្រតិភូកម្ម សម្រាប់អនុវត្តសាកល្បងផងដែរ។

ក្រៅពីនេះ តាមរយៈអនុក្រឹត្យទាំង៤ដែលប្រកាសផ្សព្វផ្សាយ និងដាក់ឱ្យអនុវត្តនាថ្ងៃនេះ ក៏តម្រូវឱ្យផ្ទេរមុខងារក្នុងវិស័យចំនួន**១៩** ដែលក្នុងនោះរួមមានមុខងារចំនួន**៥៥** និងមុខងាររងចំនួន**១៦២**ទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងមុខងារគ្រប់គ្រង និងផ្តល់សេវាសុខាភិបាលដែលអនុវត្តដោយមន្ទីរសុខាភិបាលទៅឱ្យរដ្ឋបាលរាជធានី ខេត្តផងដែរ។

ទី៤.ពាក់ព័ន្ធការធ្វើវិមជ្ឈការហិរញ្ញវត្ថុ

ច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំ និងដាក់ឱ្យប្រើប្រាស់ ដើម្បីផ្តល់ក្របខ័ណ្ឌគតិយុត្ត និងគោលការណ៍នានាសម្រាប់ការរៀបចំបង្កើតប្រភពធនធានហិរញ្ញវត្ថុ និងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ លិខិតបទដ្ឋានគតិយុត្តជាច្រើនពាក់ព័ន្ធនឹងការបង្កើតមូលនិធិក្រុង ស្រុក និងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ យន្តការផ្ទេរធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខ័ណ្ឌ ប្រភពចំណូលផ្ទាល់នៅមូលដ្ឋានរបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្តជាបន្តបន្ទាប់។ ក្នុងក្របខ័ណ្ឌនៃការធ្វើវិមជ្ឈការហិរញ្ញវត្ថុ រហូតមកដល់ពេលនេះ រាជរដ្ឋាភិបាលបានផ្ទេរថវិការដ្ឋសរុបចំនួនប្រមាណជាង**២.៩៧៨លាន**ដុល្លារ ទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់គ្រប់គ្រង ចាត់ចែង និងប្រើប្រាស់ក្រោមឆន្ទានុសិទ្ធិរបស់ខ្លួន ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

យន្តការផ្ទេរមូលនិធិមានភ្ជាប់លក្ខខ័ណ្ឌទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ក៏ត្រូវបានអនុវត្តជាបណ្តើរៗ រួមមាន យន្តការផ្ទេរធនធានហិរញ្ញវត្ថុទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់ប្រើប្រាស់លើការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារដែលបានផ្ទេរ និងយន្តការផ្ទេរធនធានមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលជាការផ្តល់ហិរញ្ញប្បទានបន្ថែមទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់អនុវត្តគម្រោងវិនិយោគសាធារណៈនានា។

សមិទ្ធផលជាគន្លឹះថ្មីមួយទៀត គឺការបង្កើនមូលនិធិឃុំ សង្កាត់ដើម្បីបង្កលក្ខណៈឱ្យក្រុមប្រឹក្សាឃុំ សង្កាត់កាន់តែមានលទ្ធភាពចូលរួមដោះស្រាយនូវតម្រូវការជាអាទិភាពនានារបស់មូលដ្ឋាននីមួយៗ។ ផ្អែកលើអនុក្រឹត្យស្តីពីការផ្ទេរធនធានបន្ថែមពីថវិការដ្ឋជូនរដ្ឋបាលឃុំ សង្កាត់ដែលបានដាក់ចេញនាខែសីហា ឆ្នាំ២០១៩កន្លងមក នៅឆ្នាំ២០២០ខាងមុខនេះ ឃុំសង្កាត់នីមួយៗនឹងទទួលបានថវិកាសរុបជាមធ្យមចំនួនប្រមាណ**១២២.០០០ដុល្លារ** ក្នុងនោះរួមមានថវិកាសម្រាប់ចំណាយលើផ្នែកអភិវឌ្ឍមូលដ្ឋានជាមធ្យមចំនួនប្រមាណជាង **៧០.០០០ដុល្លារ** ដែលចំនួននេះកើនឡើងទ្វេដងបើប្រៀបធៀបនឹងឆ្នាំ២០១៩នេះ។ ថវិកានេះនឹងកើនឡើងជារៀងរាល់ឆ្នាំ ដែលរហូតដល់ឆ្នាំ២០២៣ រដ្ឋបាលឃុំ សង្កាត់នីមួយៗនឹងទទួលបានថវិកាសរុបជាមធ្យមចំនួនជាង**១៩៤.០០០ដុល្លារ**។ ជាមួយនឹងការកើនឡើងនេះនឹងធ្វើឱ្យឃុំ សង្កាត់ធំៗមួយចំនួននឹងទទួលបានថវិកាចំនួនប្រមាណ**៤៥០.០០០ដុល្លារ**នៅឆ្នាំ២០២៣ ឧទាហរណ៍ សង្កាត់ប៉ោយប៉ែតនៃក្រុងប៉ោយប៉ែត និងឃុំក្រែកនៃស្រុកពញាក្រែកជាដើម។

ផ្អែកលើគម្រោងប៉ានស្មានសម្រាប់ឆ្នាំ២០២០ខាងមុខនេះ រដ្ឋនឹងវិភាជថវិកាចំនួនប្រមាណជាង**៨០០លានដុល្លារ**ទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ។ ចំនួននេះពុំទាន់បានគិតបញ្ចូលនូវការវិភាជពីថវិការដ្ឋទៅឱ្យរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌនីមួយៗបន្ថែមទៀតសម្រាប់អនុវត្តមុខងារដែលត្រូវផ្ទេរទៅឱ្យរដ្ឋបាលទាំងនេះ តាមរយៈអនុក្រឹត្យទាំង៤ ដែលត្រូវបានផ្សព្វផ្សាយនាថ្ងៃនេះនោះទេ។ ថវិកាបន្ថែមនេះ កំពុងត្រូវបានរៀបចំកំណត់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីផ្ទេរត្រង់ទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗគ្រប់គ្រង ចាត់ចែង និងប្រើប្រាស់ចាប់ពីដើមឆ្នាំ២០២០តទៅ។ អាស្រ័យហេតុនេះ ចំនួនថវិកាវិភាជពីថវិការដ្ឋទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់ឆ្នាំ២០២០នឹងអាចកើនឡើងរហូតដល់ជាង**១.០០០លានដុល្លារ**។

ទី៥.ពាក់ព័ន្ធនឹងស្ថាប័នគាំទ្រកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

អនុលោមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដែលហៅកាត់ថា គ.ជ.អ.ប បានបង្កើតឡើងសម្រាប់ដឹកនាំ សម្របសម្រួលដល់ការរៀបចំ និងអនុវត្តកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។ ក្រោមក្របខ័ណ្ឌនៃយន្តការនេះ គ.ជ.អ.ប. ក៏បានកៀរគរការគាំទ្រទាំងផ្នែកហិរញ្ញវត្ថុ និងផ្នែកបច្ចេកទេសពីដៃគូអភិវឌ្ឍន៍ ផ្នែកឯកជន និងអង្គការសង្គមស៊ីវិលពាក់ព័ន្ធនានាដល់អនុវត្តកម្មវិធីកំណែទម្រង់នេះ តាមរយៈការរៀបចំជាថវិកាកញ្ចប់រួមសម្រាប់គាំទ្រផ្នែកបច្ចេកទេស ឬការរៀបចំអនុវត្តគម្រោងដាច់ដោយឡែកៗក្នុងភាពជាដៃគូ និងការចូលរួមធ្វើជាដៃគូក្នុងការអនុវត្តគម្រោងនានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ផ្អែកលើការសម្របសម្រួលរបស់ គ.ជ.អ.ប. ក្រសួង ស្ថាប័នពាក់ព័ន្ធ ចំនួន២១ និងរដ្ឋបាលថ្នាក់ក្រោមជាតិ

ទូទាំងប្រទេសបានចូលរួមចំណែកយ៉ាងសកម្មក្នុងការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ តាមរយៈការរៀបចំ និងការអនុវត្តផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់ គ.ជ.អ.ប ដោយបានខិតខំបង្កើនការប្រើប្រាស់ធនធាន និងការពង្រឹងនូវយន្តការដឹកនាំការងារកំណែទម្រង់របស់ស្ថាប័ននីមួយៗ សំដៅលើកកម្ពស់ភាពជាម្ចាស់ និងការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការអនុវត្តកម្មវិធីកំណែទម្រង់នេះ។

ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី!

ទោះបីយើងសម្រេចបាននូវសមិទ្ធផលជាមូលដ្ឋានធំៗជាច្រើន ដូចបានរៀបរាប់ខាងលើក្តី ក៏នៅក្នុងក្របខ័ណ្ឌនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ យើងនៅមានកិច្ចការជាអាទិភាពជាច្រើនផ្សេងទៀតដែលត្រូវបន្តអនុវត្ត។ ក្នុងសិក្ខាសាលាជាតិនាសប្តាហ៍មុន យើងពិនិត្យពិភាក្សា និងកំណត់នូវសកម្មភាពជាអាទិភាពនានាដែលត្រូវអនុវត្តនៅក្នុងឆ្នាំ២០២០ រួមមានសកម្មភាពពាក់ព័ន្ធនឹងការលើកកម្ពស់តួនាទី និងការទទួលខុសត្រូវរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌក្នុងការផ្តល់សេវាសាធារណៈ ស្របតាមមុខងារ និងរចនាសម្ព័ន្ធថ្មី ការធានាប្រសិទ្ធភាពនៃការប្រើប្រាស់មូលនិធិឃុំ សង្កាត់ ការពង្រឹងកិច្ចដំណើរការសាលាជាតិរដ្ឋបាលមូលដ្ឋាន ការលើកកម្ពស់ភាពជាដៃគូរវាងរដ្ឋបាលថ្នាក់ក្រោមជាតិជាមួយសហគមន៍មូលដ្ឋាន អង្គការសង្គមស៊ីវិល និងវិស័យឯកជននានា។ ទាំងនេះ គឺជាកិច្ចការអាទិភាពសម្រាប់ឆ្នាំ២០២០ ដែលជាឆ្នាំចុងក្រោយនៃកម្មវិធីជាតិរយៈពេល១០ឆ្នាំ។

ទោះយ៉ាងនេះក្តី ដូចខ្ញុំបានគូសបញ្ជាក់ពីខាងដើមរួចមកហើយថា រាជរដ្ឋាភិបាលមានឆន្ទៈនយោបាយ និងទស្សនៈវិស័យរយៈពេលវែងចំពោះកំណែទម្រង់វិមជ្ឈការ។ ទោះបីកម្មវិធីជាតិរយៈពេល១០នឹងត្រូវបញ្ចប់នៅចុងឆ្នាំ២០២០ខាងមុខនេះក៏ដោយ ក៏ផ្អែកតាមយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ និងផ្អែកលើមេរៀនបទពិសោធន៍នៃការអនុវត្តកន្លងមក រាជរដ្ឋាភិបាលនឹងបន្តរៀបចំតាក់តែង និងដាក់ឱ្យអនុវត្តនូវកម្មវិធីជាតិរយៈពេលវែងថ្មីមួយទៀតដែលត្រូវចាប់ផ្តើមអនុវត្តពីឆ្នាំ២០២១តទៅ។ ពាក់ព័ន្ធនឹងកិច្ចការដ៏សំខាន់នេះ ខ្ញុំសូមគូសបញ្ជាក់នូវកិច្ចការជាអាទិភាពមួយចំនួនដែលត្រូវពិចារណាសម្រាប់ការរៀបចំកម្មវិធីជាតិជំហានបន្ទាប់ រួមមាន៖

ទី១៖ ការបន្តរៀបចំស្ថាប័នរដ្ឋបាលថ្នាក់ក្រោមជាតិ៖ ពាក់ព័ន្ធនឹងកិច្ចការនេះ ក្រៅពីការពង្រឹងតួនាទី និងការទទួលខុសត្រូវរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌក្នុងការផ្តល់សេវាសាធារណៈស្របតាមមុខងារ និងរចនាសម្ព័ន្ធដែលបានកែសម្រួលថ្មី ក៏ត្រូវបន្តធ្វើការសិក្សាលើជម្រើសនានាសម្រាប់ការកែសម្រួលនូវរចនាសម្ព័ន្ធគ្រប់គ្រងនៅថ្នាក់រាជធានី ខេត្ត ដើម្បីបែងចែកឱ្យបានកាន់តែច្បាស់លាស់នូវមុខងារ តួនាទី និងការទទួលខុសត្រូវរវាងរដ្ឋបាលថ្នាក់ក្រោមជាតិតាមប្រភេទនីមួយៗ ជាអាទិ៍៖

- **ថ្នាក់ខេត្ត**៖ ជាថ្នាក់រដ្ឋបាលដែលមានចរិកលក្ខណៈជារដ្ឋបាល**ថ្នាក់តំបន់** ដោយមានមុខងារ តួនាទី និងការទទួលខុសត្រូវក្នុងការ៖ (១) អនុវត្តមុខងារជាតំណាងរាជរដ្ឋាភិបាល ក្រសួង ស្ថាប័ននៅថ្នាក់ជាតិក្នុងការសម្របសម្រួល និងគាំទ្រដល់រដ្ឋបាលមូលដ្ឋានក្នុងដែនដីរបស់ខ្លួន (២) អនុវត្តមុខងារដែលថ្នាក់ជាតិបានធ្វើប្រតិភូកម្មឱ្យជាពិសេស មុខងារដែលពាក់ព័ន្ធនឹងសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ច្បាប់ យុត្តិធម៌សង្គម ឬមុខងារពាក់ព័ន្ធនឹងការផ្តល់សេវាសង្គមមួយចំនួន និង (៣) អនុវត្តមុខងារផ្តល់សេវា និងគម្រោងវិនិយោគធំៗមួយចំនួនដែលផ្តល់ផលប៉ះពាល់ក្នុងក្របខណ្ឌនៃខេត្តទាំងមូល និងដែលមិនអាចរ៉ាប់រង ឬអនុវត្តដោយរដ្ឋបាលមូលដ្ឋាន។
- **ថ្នាក់ក្រុង ស្រុក និងថ្នាក់ឃុំ**៖ ជាថ្នាក់រដ្ឋបាលដែលមានចរិកលក្ខណៈជារដ្ឋបាលមូលដ្ឋានស្ថិតនៅកៀកជិតប្រជាពលរដ្ឋ មានការប្រាស្រ័យទាក់ទងដោយផ្ទាល់ជាមួយប្រជាពលរដ្ឋ ព្រមទាំងមានមុខងារ តួនាទី និងការទទួលខុសត្រូវក្នុងការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋាន ដើម្បីឆ្លើយតប និងដោះស្រាយបញ្ហានានារបស់ប្រជាពលរដ្ឋដោយផ្ទាល់ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។
- **រាជធានីភ្នំពេញ**៖ ជារដ្ឋបាលដែលមានចរិកលក្ខណៈជារដ្ឋបាលមូលដ្ឋានពិសេសមួយ ដែលតម្រូវឱ្យមានរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងដោយឡែកខុសពីប្រភេទរដ្ឋបាលមូលដ្ឋានខាងលើ។

ទន្ទឹមគ្នានេះ ក៏ត្រូវបន្តការសិក្សាលើជម្រើសនានាដើម្បីកំណត់នូវសក្តានុពលនៃខេត្ត ឬក្រុងមួយចំនួនដែលអាចរៀបចំឱ្យក្លាយទៅជារដ្ឋបាលស្វយ័តសម្រាប់ពេលអនាគត។

ទី២.ការគ្រប់គ្រង និងអភិវឌ្ឍធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិ៖ ត្រូវបន្តពង្រឹងប្រព័ន្ធគ្រប់គ្រង និងអភិវឌ្ឍធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីធានាឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិមានសមត្ថភាពផ្នែកស្ថាប័នកាន់តែរឹងមាំ មានបុគ្គលិកប្រកបដោយសមត្ថភាពជំនាញ សីលធម៌វិជ្ជាជីវៈ និងនវានុវត្តន៍ ដោយប្រកាន់ខ្ជាប់នូវគោលការណ៍ឆន្ទៈម្ចាស់ការ មនសិការវិជ្ជាជីវៈ ភក្តីភាព និងវប្បធម៌សេវាសាធារណៈ បំពេញការងារដោយមានការទទួលខុសត្រូវ និងមានគណនេយ្យភាពច្បាស់លាស់។

ទី៣.ការផ្ទេរមុខងារទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ៖ ទន្ទឹមនឹងការបន្តគាំទ្រ និងជំរុញឱ្យការអនុវត្តមុខងារដែលបានផ្ទេរឱ្យប្រកបដោយប្រសិទ្ធភាពខ្ពស់ ក៏ត្រូវបន្តជំរុញការផ្ទេរមុខងារឱ្យបានកាន់តែច្រើនទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ និងត្រូវសិក្សាដើម្បីអភិវឌ្ឍប្រព័ន្ធផ្តល់សេវារបស់រដ្ឋបាលថ្នាក់ក្រោមជាតិតាមប្រព័ន្ធព័ត៌មានវិទ្យា ស្វ័យប្រវត្តិកម្ម និងការប្រើប្រាស់បច្ចេក

ទេសទាន់សម័យប្រកបដោយភាពវៃឆ្លាត ដែលធានាដល់ការផ្តល់សេវាកាន់តែមានគុណភាព ប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព បរិយាប័ន្ន និងសមធម៌សង្គម។

ទី៤.ការធ្វើវិមជ្ឈការហិរញ្ញវត្ថុ៖ ក្រៅពីការពង្រឹងសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការគ្រប់គ្រង ចាត់ចែង និងប្រើប្រាស់ថវិកាសាធារណៈឱ្យកាន់តែមានប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព ចាំបាច់ត្រូវបន្តការសិក្សាលើជម្រើសនានាសម្រាប់ការបង្កើតប្រភពចូលផ្ទាល់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីធានាដល់ការកៀរគរធនធានបន្ថែម និងពង្រឹងភាពម្ចាស់ការក្នុងការប្រើប្រាស់ធនធានប្រកដោយនិរន្តរភាព គណនេយ្យភាព និងសមធម៌សង្គម។

ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី!

នាពេលបន្តិចទៀតនេះ តំណាងលេខាធិការដ្ឋាន គ.ជ.អ.ប. និងតំណាងក្រសួងសុខាភិបាលនឹងធ្វើបទបង្ហាញអំពីខ្លឹមសារលម្អិតនៃអនុក្រឹត្យស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងអនុក្រឹត្យស្តីពីការប្រគល់មុខងារគ្រប់គ្រង និងផ្តល់សេវាសុខាភិបាលទៅឱ្យរដ្ឋបាលរាជធានី ខេត្ត ព្រមទាំងផែនការសកម្មភាព និងក្របខ័ណ្ឌពេលវេលាសម្រាប់ការអនុវត្តអនុក្រឹត្យទាំង៤នេះ។ ទោះយ៉ាងនេះក្តី ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមផ្តល់គោលការណ៍ណែនាំមួយចំនួនដែលត្រូវផ្តោតការយកចិត្តទុកដាក់អនុវត្ត ដើម្បីធានាឱ្យរចនាសម្ព័ន្ធថ្មីរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងមុខងារនានាដែលត្រូវបានផ្ទេរឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិអាចអនុវត្តទៅបានចាប់ពីដើមឆ្នាំ២០២០តទៅ ស្របតាមស្មារតីនៃអនុក្រឹត្យទាំងនេះ។

ទីមួយ៖ <u>អំពីរៀបចំធ្វើសមាហរណកម្មការិយាល័យ អង្គភាពនានា និងការផ្ទេរបុគ្គលិកទៅក្នុងរចនាសម្ព័ន្ធថ្មីនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ</u>

ផ្អែកតាមស្មារតីនៃអនុក្រឹត្យទាំងនេះ លេខាធិការដ្ឋាន គ.ជ.អ.ប តាមរយៈក្រុមការងារអន្តរក្រសួងសម្រាប់រៀបចំផ្ទេរបុគ្គលិក ត្រូវរៀបចំសេចក្តីណែនាំស្តីពីការធ្វើសមាហរណកម្ម និងការរៀបចំបុគ្គលិកទៅក្នុងរចនាសម្ព័ន្ធថ្មីនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងត្រូវរៀបចំកិច្ចប្រជុំផ្សព្វផ្សាយដល់មន្ត្រីទទួលបន្ទុកនៅថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។ កិច្ចការនេះត្រូវអនុវត្តជាបន្ទាន់ចាប់ពីពេលនេះតទៅ ដើម្បីធានាឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌសាមីអាចចាប់ផ្តើមប្រមូលនិងចងក្រងទិន្នន័យបុគ្គលិកដែលត្រូវធ្វើសមាហរណកម្មចូលទៅតាមការិយាល័យ និងអង្គភាពនានានៃរចនាសម្ព័ន្ធថ្មីរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ សម្រាប់ផ្ញើមកលេខាធិការដ្ឋាន គ.ជ.អ.ប. ដើម្បីផ្ទៀងផ្ទាត់ និងធ្វើជាមូលដ្ឋានក្នុងការរៀបចំសេចក្តីព្រាងសេចក្តីសម្រេចស្តីពីការធ្វើសមារណកម្ម និងការរៀបចំបុគ្គលិកតាមការិយាល័យ និងអង្គភាពនានាក្នុងរចនាសម្ព័ន្ធថ្មីនៃរដ្ឋបាល ក្រុង ស្រុក ខណ្ឌ សម្រាប់ដាក់ជូន គ.ជ.អ.ប. ពិនិត្យ និងសម្រេចក្នុងអំឡុងខែមករា ឆ្នាំ២០២០។ ចាប់ពីពេលនេះ ស្នើក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបន្តរក្សាកន្លែងធ្វើការងារ

របស់បុគ្គលិកនៅថ្នាក់ក្រុង ស្រុក ខណ្ឌ ដោយមិនអនុញ្ញាតឱ្យមានការផ្ទេរ ឬផ្លាស់ប្តូរកន្លែងធ្វើការងាររបស់បុគ្គលិក ដើម្បីផ្តល់ភាពងាយស្រួលដល់ការធ្វើសមាហរណកម្មនេះ។

ឆីពីរ៖ <u>អំពីការផ្ទេរធនធានហិរញ្ញវត្ថុ ទ្រព្យសម្បត្តិ និងសិទ្ធិ កាតព្វកិច្ច និងការទទួលខុសត្រូវ</u>

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងលេខាធិការដ្ឋាន គ.ជ.អ.ប. ត្រូវបន្តខិតខំសម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធនានាក្នុងការកំណត់អំពីចំនួនថវិកាជាក់លាក់ រួមមានថវិកាសម្រាប់បន្ទុកបុគ្គលិក ថវិកាសម្រាប់ប្រតិបត្តិការ និងថវិកាសម្រាប់អនុវត្តមុខងារដែលបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងការរៀបចំលិខិតបទដ្ឋានបច្ចេកទេសនានាដើម្បីផ្ទេរធនធានទាំងនេះឱ្យបានទាន់ពេលវេលាទៅឱ្យរដ្ឋបាលរាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌក្នុងការចាប់ផ្តើមបំពេញមុខងារដែលបានផ្ទេរឱ្យទាំងនោះចាប់ដើមឆ្នាំ២០២០តទៅ។ ជាមួយគ្នានេះ ក៏ត្រូវពិនិត្យ និងកែសម្រួលនូវប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌឱ្យឆ្លើយតបទៅនឹងរចនាសម្ព័ន្ធគ្រប់គ្រងថ្មីនៃរដ្ឋបាលទាំងនោះផងដែរ។

ក្នុងករណីទ្រព្យសម្បត្តិជាអចលនទ្រព្យមួយចំនួន ដែលពុំអាចមានលទ្ធភាពរៀបចំផ្ទេរទាន់ពេលវេលា ក្រសួង ស្ថាប័ននានាត្រូវអនុញ្ញាតឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិប្រើប្រាស់នូវទ្រព្យសម្បត្តិទាំងនោះជាបណ្តោះអាសន្ន និងត្រូវបន្តរៀបចំផ្ទេរទ្រព្យសម្បត្តិឱ្យបានមុនដំណាច់ឆមាសទី១ ឆ្នាំ២០២០ខាងមុខនេះ។

គ.ជ.អ.ប. នឹងដាក់ចេញនូវសេចក្តីណែនាំស្តីពីការរៀបចំផ្ទេរសិទ្ធិ កាតព្វកិច្ច និងការទទួលខុសត្រូវពីការិយាល័យជំនាញទៅឱ្យស្ថិតក្រោមការគ្រប់គ្រងរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌស្របតាមរចនាសម្ព័ន្ធថ្មី ដូចមានកំណត់ក្នុងអនុក្រឹត្យ។ រដ្ឋបាលរាជធានី ខេត្តត្រូវផ្តល់ការគាំទ្រ និងជួយសម្របសម្រួលដល់ការរៀបចំជាក់ស្តែងចំពោះកិច្ចការទាំងនេះ។

ឆីបី៖ <u>អំពីការរៀបចំលិខិតបទដ្ឋាន និងឯកសារណែនាំបច្ចេកទេសនានា</u>

ដើម្បីធានាឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិអាចដំណើរការតាមរចនាសម្ព័ន្ធថ្មី និងចាប់ផ្តើមទទួលខុសត្រូវលើការផ្តល់សេវាតាមមុខងារនានា ដែលបានផ្ទេរឱ្យចាប់ពីដើមឆ្នាំ២០២០តទៅ តម្រូវឱ្យមានការរៀបចំនូវសេចក្តីណែនាំបច្ចេកទេសស្តីពីគោលការណ៍ បែបបទ នីតិវិធី និងស្តង់ដាផ្តល់សេវាតាមវិស័យនានាដែលបានផ្ទេរឱ្យទាំងនោះ។ ក្នុងករណីដែលមុខងារណាមួយពុំទាន់មានការកំណត់អំពីនីតិវិធី និងស្តង់ដាសម្រាប់ការផ្តល់សេវាទេនោះ រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវខិតខំផ្ពួចផ្តើមគំនិតក្នុងការផ្តល់សេវានោះប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់។ ចំពោះរដ្ឋបាលរាជធានីភ្នំពេញក៏តម្រូវឱ្យធ្វើប្រតិភូកម្មមុខងារនានាទៅឱ្យរដ្ឋបាលខណ្ឌផងដែរ។ ដោយឡែកចំពោះការប្រគល់មុខងារក្នុងវិស័យសុខាភិបាល ក៏តម្រូវឱ្យរៀបចំនូវប្រកាសអន្តរក្រសួងស្តីពីការ

រៀបចំ និងការប្រព្រឹត្តទៅនៃមន្ទីរសុខាភិបាលនៃរដ្ឋបាលរាជធានី ខេត្តផងដែរ។

ក្នុងន័យនេះ ក្រសួងសាមីពាក់ព័ន្ធនីមួយៗត្រូវរួសរាន់រៀបចំសេចក្តីណែនាំបច្ចេកទេសទាំងនេះឱ្យបានទាន់ពេលវេលា។ អគ្គនាយកដ្ឋានរដ្ឋបាលក្រសួងមហាផ្ទៃត្រូវសហការជាមួយក្រសួងសុខាភិបាល ដើម្បីរៀបចំប្រកាសអន្តរក្រសួងស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃមន្ទីរសុខាភិបាលរបស់រដ្ឋបាលរាជធានី ខេត្ត និងរៀបចំការណែនាំអំពីកម្មវិធី និងរបៀបរៀបចំការប្រកាសដាក់ឱ្យអនុវត្តនូវរចនាសម្ព័ន្ធនេះនៅតាមរាជធានី និងខេត្តនីមួយៗឱ្យបានយ៉ាងយូរនាចុងឆ្នាំ ២០១៩។ ជាមួយគ្នានេះ អគ្គនាយកដ្ឋានរដ្ឋបាលក្រសួងមហាផ្ទៃក៏ត្រូវសម្របសម្រួល និងផ្តល់ការគាំទ្រផ្នែកបច្ចេកទេសដល់រដ្ឋបាលរាជធានីភ្នំពេញក្នុងការរៀបចំដីកា ដើម្បីធ្វើប្រតិភូកម្មមុខងារដែលបានកំណត់ក្នុងអនុក្រឹត្យទៅឱ្យរដ្ឋបាលខណ្ឌក្នុងចុងឆ្នាំ២០១៩នេះផងដែរ។

ឆមួន៖ <u>អំពីការបណ្តុះបណ្តាល</u>

ជារួម ដើម្បីធានាឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិអាចដំណើរការតាមរចនាសម្ព័ន្ធគ្រប់គ្រងថ្មី និងអាចគ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារនានាដែលបានផ្ទេរឱ្យប្រកបដោយប្រសិទ្ធភាព ចាំបាច់ត្រូវផ្តល់ការអភិវឌ្ឍសមត្ថភាពជាច្រើនបន្ថែមទៀតដល់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ។ ទោះយ៉ាងនេះក្តី ក្នុងដំណាក់កាលចំពោះមុខ ត្រូវផ្តល់អាទិភាពដល់ការបណ្តុះបណ្តាលអំពីប្រធានបទមួយចំនួន រួមមាន អំពីមុខងារ និងរចនាសម្ព័ន្ធថ្មីរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ អំពីគោលការណ៍ បែបបទ នីតិវិធី និងស្តង់ដាសម្រាប់ការផ្តល់សេវាតាមវិស័យនានាដែលបានផ្ទេរឱ្យ អំពីគោលការណ៍ បែបបទ និងនីតិវិធីនៃការគ្រប់គ្រងបុគ្គលិក អំពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ ដែលបានកែសម្រួលជាដើម។ ក្នុងន័យនេះ សាលាជាតិរដ្ឋបាលមូលដ្ឋានត្រូវសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធក្នុងការរៀបចំវគ្គបណ្តុះបណ្តាលទាំងនេះដល់រដ្ឋបាលក្រុង ស្រុក ខណ្ឌទាំងអស់យ៉ាងយូរក្នុងអំឡុងត្រីមាសទី១នៃឆ្នាំ២០២០។ វគ្គបណ្តុះបណ្តាលចាំបាច់ផ្សេងទៀត ត្រូវរៀបចំតាមពេលវេលាជាបន្តបន្ទាប់។

ឆជ្រាំ៖ <u>អំពីភាពម្ចាស់ការក្នុងការអនុវត្តអនុក្រឹត្យ</u>

រដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេសថ្នាក់ដឹកនាំក្រុង ស្រុក ខណ្ឌត្រូវផ្តោតការយកចិត្តទុកដាក់ក្នុងការពង្រឹងភាពម្ចាស់ការ និងការទទួលខុសត្រូវក្នុងការដឹកនាំ ការគ្រប់គ្រង ការចាត់ចែងបុគ្គលិក និងធនធាននានាសម្រាប់ផ្តល់សេវាតាមវិស័យនានាដែលបានផ្ទេរឱ្យប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព។

អគ្គនាយកដ្ឋានរដ្ឋបាលក្រសួងមហាផ្ទៃត្រូវសហការជាមួយលេខាធិការដ្ឋាន គ.ជ.អ.ប. និងក្រសួង ស្ថាប័នពាក់ព័ន្ធក្នុងការតាមដានត្រួតពិនិត្យ និងវាយតម្លៃលើការបំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងត្រូវធ្វើសេចក្តីរាយការណ៍ឱ្យបានទៀងទាត់ជូន គ.ជ.អ.ប. ដើម្បី

ផ្តល់អន្តរាគមន៍ ឬចាត់វិធានការផ្សេងៗទៀតដើម្បីដោះស្រាយឱ្យបានទាន់ពេលវេលា។

ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី!

មុននឹងបញ្ចប់ ក្នុងនាមរាជរដ្ឋាភិបាល ក្នុងនាម គ.ជ.អ.ប. ខ្ញុំសូមអំពាវនាវឱ្យមានការចូលរួមគាំទ្រឱ្យកាន់តែសកម្មបន្ថែមទៀតពីឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ដែលជាតំណាងស្ថាប័ននីតិប្បញ្ញត្តិ ថ្នាក់ដឹកនាំ និងជាមន្ត្រីនៃក្រសួង ស្ថាប័ននានាទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល ផ្នែកឯកជន និងអ្នកពាក់ព័ន្ធនានា ដល់កិច្ចដំណើរការកំណែទម្រង់ដ៏មានសារៈសំខាន់នេះ ឱ្យសម្រេចបានជោគជ័យតាមគោលបំណងដែលបានគ្រោងទុក។

មុននឹងបញ្ចប់ ខ្ញុំសូមគូសបញ្ជាក់អះអាងជាថ្មីអំពីការតាំងចិត្តដ៏មោះមុតរបស់រាជរដ្ឋាភិបាលក្នុងការបន្តអនុវត្តឱ្យកាន់តែស៊ីជម្រៅនូវកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ព្រមទាំងកំណែទម្រង់សំខាន់ៗដទៃទៀតដើម្បីរួមចំណែកជំរុញល្បឿននៃការអភិវឌ្ឍប្រទេសជាតិ និងការលើកកម្ពស់ជីវភាពរបស់ប្រជាពលរដ្ឋឱ្យកាន់តែមានភាពចម្រើនរុងរឿង។

ខ្ញុំសូមជូនពរអង្គពិធីទាំងមូល សូមប្រកបដោយពុទ្ធពរទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ និង**សូមប្រកាសផ្សព្វផ្សាយ និងដាក់ឱ្យអនុវត្តអនុក្រឹត្យទាំង៤នេះ ចាប់ពីពេលនេះតទៅ**។

សូមអរគុណ!